ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ ០០៤/០៥/២០០៧ កបធ

# ការប្រញាប់

## សូមក្រាបបង្គំទូលថ្វាយ

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

**<u>កម្មវត្ថុ</u>** : សេចក្តីថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីអំពីការផ្តើមគំនិតធ្វើវិសោធនកម្មមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី ជំពូកទី ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**<u>យោង</u>** : ព្រះរាជសារ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧

ទូលព្រះបង្គំយើងខ្ញុំ ជាប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយតាមមតិភាគច្រើនបានសម្រេចក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត ដូចតទៅ :**

១-សេចក្តីផ្តើមគំនិតធ្វើវិសោធនកម្មនៃមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី នៃជំពូកទី ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺសំដៅធានាឱ្យបាននូវការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់រដ្ឋបាលជាតិគ្រប់កម្រិត តាមក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍-ជាតិ ឆ្នាំ ២០០៦ -២០១០ ។

មាត្រា ១៥១ ថ្មី ( មាត្រា ១៣២ ចាស់ ) នៃរដ្ឋធម្មនុញ្ញ ចែងថា *"ការផ្តើមគំនិតសើរើ ឬ ការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល"* ។

មាត្រា ១៥២ ថ្មី ( មាត្រា ១៣៣ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា *"ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦"* ។

មាត្រា ១៥៣ ថ្មី( មាត្រា ១៣៤ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា *"ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ"* ។

តាមការពិនិត្យ និង ពិចារណាដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រាដូចបានក្រាបបង្គំទូលថ្វាយខាងលើនេះ ខ្លឹមសារការធ្វើវិសោធនកម្មមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញ ពុំមានអ្វីប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញឡើយ ព្រមទាំងធ្វើឡើងនៅក្នុងកាលៈទេសៈធម្មតារបស់ប្រទេសជាតិ ថែមទៀតផង ។

២-ក្រុមប្រឹក្សាធម្មនុញ្ញ យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ១៤៥ ថ្មី និង មាត្រា ១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ខាងលើនេះ អាចធ្វើបាន ។

**សូមព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាព និង ការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ យើងខ្ញុំ**

ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល